# បោះឆ្នោតនៅចន្លោះ ថ្ងៃច័ន្ទ ទី ៥ ខែតុលា ដល់ថ្ងៃអង្គារ៍ ទី ៣ ខែវិច្ឆិកា

## មគ្គុទេសន៍ណែនាំអ្នកបោះឆ្នោត Long Beach Rising

ស្បែកខ្មៅ, ស្បែកស, ស្បែកត្នោត ឬខ្មែរ; ជនជាតិដើម ឬជនអន្តោប្រវេសន៍; មនុស្សវ័យក្មេង ឬមនុស្សចាស់: យើងទាំងអស់គ្នាជឿជាក់លើទីក្រុងឡុងប៊ីឆ ដែលគ្រប់គ្នាអាចទទួលបាននូវភាពជោគជ័យ។ ប៉ុន្តែមកទល់ថ្ងៃនេះ, អ្នកនយោបាយ និងអ្នកបញ្ចុះបញ្ចូលលោភលន់ជាក់លាក់មួយចំនួន ដែលគាំទ្រពួកគេ ធ្វើឱ្យមនុស្សគ្រប់គ្នាឈឺចាប់ ដោយប្រគល់ប្រាក់ទៅឱ្យក្រុមហ៊ុនសាជីវកម្មនានា, ផ្តាច់ថវិការសាលារៀននានារបស់យើង, ធ្វើឱ្យចុះខ្សោយសេវាកម្មដល់សហគមន៍, និងធ្វើឱ្យអ្នកជិតខាងរបស់យើងផ្លាស់ទីលំនៅ។ វាមិនចាំបាច់ មាននូវវិធីទាំងនេះទេ។ យើងហួសពេលជាយូរមកហើយ ដើម្បីសរសេរច្បាប់ឡើងវិញ ហើយធ្វើឱ្យសម្លេងរបស់យើងត្រូវបានគេឮ។ ការបោះឆ្នោតរបស់យើង គឺជាអំណាចរបស់យើង។ ចាប់ពីកំណែទំរង់លំនៅដ្ឋានដែលមានតំលៃសមរម្យ រហូតដល់កំណែទំរង់យុត្តិធម៌, និងកិច្ចការពារកម្មករ ដើម្បីទទួលបាននូវឱកាសស្មើគ្នាសម្រាប់ទាំងអស់គ្នា: យើងរៀបចំធ្វើឱ្យមានអនាគត ដោយចូលរួមទាំងអស់គ្នា ជាអ្នកបោះឆ្នោត។

ចូលរួមជាមួយ Long Beach Rising! សម្ព័ន្ធភាពនៅក្នុងវដ្តនៃការបោះឆ្នោតនេះ ដើម្បីកសាងឡុងប៊ីឆនាពេលអនាគត ដែលយើងដឹងថាអាចទៅរួច! នៅចន្លោះថ្ងៃទី ៥ ខែតុលា រហូតដល់ថ្ងៃទី ៣ ខែវិច្ឆិកា, យើងស្នើសុំឱ្យអ្នកចូលរួមជាមួយនឹងពួកយើង ក្នុងការផ្តល់អាទិភាពដល់គ្រួសារទាំងឡាយ ដែលកំពុងធ្វើការ ដោយបោះឆ្នោតលើវិធានការណ៍សន្លឹកឆ្នោតនានាទាំងនេះ នៅថ្នាក់ក្រុង, ស្រុក, និងថ្នាក់រដ្ឋ។

**វិធានការណ៍អាមេរិក – បាទ/ចាស (MEASURE US – YES)**

ធ្វើឱ្យក្រុមហ៊ុនប្រេងនានា ដែលកំពុងខួងអណ្តូងប្រេងនៅឡុងប៊ីឆ ទទួលខុសត្រូវក្នុងការបង់ចំណែកដោយយុត្តិធម៌របស់ពួកគេ ក្នុងពន្ធផលិតកម្មប្រេង។ ប្រាក់ចំណូលនឹងទៅដល់សហគមន៍ដែលបានរងផលប៉ះពាល់ភាគច្រើន ពីការប្រកាន់ពូជសាសន៍ជាលក្ខណៈប្រព័ន្ធ និងបរិស្ថាន។

**វិធានការណ៍ J – បាទ/ចាស (MEASURE J – YES)**

វិធានការណ៍ J នឹងផ្លាស់ប្តូរប្រហែល ១ ពាន់លានដុល្លារក្នុងមួយឆ្នាំ ចំពោះថវិការខោនធី ពីគោលនយោបាយនានាដែលធ្វើឱ្យប៉ះពាល់ដល់សហគមន៍ខ្មៅ និងត្នោត ទៅជាកម្មវិធីនានាដែលធ្វើឱ្យប្រសើរឡើងនូវសហគមន៍ដដែល

ទាំងនោះ — សុខភាព, លំនៅដ្ឋាន, និងការងារ។ វិធានការណ៍ ៗ គឺជាវិធីដែលយើងចាប់ផ្តើមដោះស្រាយនូវកំហុសនៃអយុត្តិធម៌ពូជសាសន៍ ក្នុងអិលអេខោនធី។

**សំណើរ 14 – បាទ/ចាស (PROPOSITION 14 – YES)**
ផ្តល់សិទ្ធិមូលបត្របំណុលរដ្ឋ ចំនួន ៥.៥ ពាន់លានដុល្លារ សម្រាប់ការស្រាវជ្រាវកោសិកាដើម។ ថវិការសាធារណៈគឺជាមធ្យោបាយដ៏ប្រសើរបំផុត ក្នុងការគាំទ្រវិទ្យាសាស្ត្រមូលដ្ឋាន និងធានាថាផលប្រយោជន៍សាធារណៈ ពីការស្រាវជ្រាវ, ជំនួសឱ្យការវិនិយោគ និងការអភិវឌ្ឍន៍ឯកជនណាមួយ ដែលត្រូវបានជម្រុញ ឬលើកទឹកចិត្តដោយការរកប្រាក់ចំណេញ។

**សំណើរ 15 – បាទ/ចាស (PROPOSITION 15 – YES)**
បង្កើនថវិការសម្រាប់សាលាសាធារណៈ K-12,  មហាវិទ្យាល័យសហគមន៍, និងរដ្ឋាភិបាលក្នុងតំបន់ ដោយតំរូវឱ្យយកពន្ធអចលនទ្រព្យពាណិជ្ជកម្ម និងឧស្សាហកម្ម ដោយផ្អែកលើតំលៃទីផ្សារបច្ចុប្បន្ន។ សំណើរ ១៥ ត្រូវបានប៉ាន់ប្រមាណថា នឹងនាំមកនូវថវិការចំនួន ៣៣.៧ លានដុល្លារ ដល់មូលនិធិទូទៅនៃទីក្រុងឡុងប៊ីឆ ជារៀងរាល់ឆ្នាំដើម្បីអោយយើងអាចតស៊ូមតិសម្រាប់ធនធានបន្ថែមទៀត ដាក់ទៅអោយអាទិភាពនានារបស់សហគមន៍ ដូចជាលំនៅដ្ឋាន, សេវាកម្មសុខភាព, និងយុវជន និងការធ្វើកម្មវិធីមនុស្សចាស់។

**សំណើរ 16 – បាទ/ចាស (PROPOSITION 16 – YES)**
សំណើរ ១៦ នឹងអនុញ្ញាតឱ្យមានសកម្មភាពជាវិជ្ជមាន នៅក្នុងរដ្ឋកាលីហ្វ័រញ៉ាជាជំហ៊ានជាក់ស្តែងមួយ ដែលយើងអាចអនុវត្តដើម្បីចាប់ផ្តើមដកចេញនូវឧបសគ្គនានា ដើម្បីទទួលបានឱកាសស្មើគ្នាសម្រាប់ទាំងអស់គ្នា។ ជាមួយនឹងសកម្មភាពជាវិជ្ជមាន, ស្ត្រី និងអ្នកដែលមានពណ៌សម្បុរទាំងឡាយ អាចទទួលបានប្រាក់ឈ្នួលខ្ពស់, មានលទ្ធភាពទទួលបាននូវការអប់រំខ្ពស់, ហើយអាចប្រកួតប្រជែងលើជំហ៊ារដោយស្មើភាពគ្នា សម្រាប់កិច្ចសន្យារដ្ឋនានា។

**សំណើរ 17 – បាទ/ចាស (PROPOSITION 17 – YES)**
វិធានការណ៍នេះ នឹងស្តារសិទ្ធិបោះឆ្នោតដល់ប្រជាជនកាលីហ្វ័រញ៉ាជិត ៤0,000 នាក់ ដែលត្រូវបានដោះលែងពីពន្ធនាគារ ប៉ុន្តែនៅតែស្ថិតក្នុងលក្ខ័ណ្ឌពេលដោះលែង ឬ on parole, ដោយធានាបាននូវអ្នកតំណាងកាន់តែច្រើន និងលទ្ធិប្រជាធិបតេយ្យ ប្រកបដោយប្រសិទ្ធភាព។ រដ្ឋកាលីហ្វ័រញ៉ានឹងក្លាយជារដ្ឋទី ២០ ដែលអនុញ្ញាតិឱ្យបុគ្គលដែលស្ថិតក្នុងលក្ខ័ណ្ឌពេលដោះលែង ចូលរួមក្នុងការបោះឆ្នោត ប្រសិនបើត្រូវបានអនុម័ត។

**សំណើរ 18 – បាទ/ចាស (PROPOSITION 18 – YES)**

ពង្រីកអ្នកបោះឆ្នោត ដោយអនុញ្ញាតឱ្យអ្នកដែលមានអាយុ ១៧ ឆ្នាំ អាចបោះឆ្នោតបាន។ ធ្វើដូចនេះ ពង្រឹងគុណតម្លៃប្រជាធិបតេយ្យរបស់យើង ដោយផ្តល់ឱ្យមនុស្សវ័យក្មេងនូវសំឡេងមួយជាមុន នៅក្នុងដំណើរការ និងអនុញ្ញាតិឱ្យពួកគេ ចូលរួមក្នុងការបោះឆ្នោតបឋម ដែលសំរេចចិត្តបេក្ខជននានា សម្រាប់ការបោះឆ្នោតទូទៅ និងបង្កើតនូវវប្បធម៌នៃការចូលរួមរបស់ពលរដ្ឋ។

**សំណើរ 19 – ទេ (PROPOSITION 19 – NO)**

វិធានការណ៍នេះ គឺជាការលើកលែងពន្ធលើអចលនទ្រព្យ ដែលផ្តល់ផលប្រយោជន៍ដល់ម្ចាស់ផ្ទះដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ ក្នុងការទិញផ្ទះដែលមានតម្លៃថ្លៃជាងមុន ខណៈពេលដែលអនុញ្ញាតឱ្យពួកគេ រក្សាបាននូវការវាយតម្លៃពន្ធ លើអចលនទ្រព្យទាបជាងមុន របស់ពួកគេ។ ធ្វើដូចនេះ ផ្លាស់ប្តូរការចំណាយដល់ម្ចាស់ផ្ទះថ្មី និងបង្កើនវិសមភាពនៅក្នុងទីផ្សារលំនៅដ្ឋាន។

**សំណើរ 20 – ទេ (PROPOSITION 20 – NO)**

សហគមន៍វិលត្រឡប់មកវិញ ឈ្នះពីសំណើរ ៤៧ និង ៥៧ និងបង្កើនភាពអយុត្តិធម៌ពូជសាសន៍។ វិធានការណ៍នេះ នឹងបង្កើនចំនួនអ្នកទោសចំនួន ១០,០០០ នាក់ ក្នុងមួយឆ្នាំៗ និងបង្កើនថវិការពន្ធនាគារ ខណៈពេលដែល រដ្ឋកាលីហ្វ័រញ៉ាបានឃ្លាតចាកឆ្ងាយពីការជាប់ឃុំឃាំងទ្រង់ទ្រាយធំ ក្នុងរយៈពេលជាច្រើនឆ្នាំចុងក្រោយនេះ។

**សំណើរ 21 – បាទ/ចាស (PROPOSITION 21 – YES)**

វិធានការណ៍នេះ អនុញ្ញាតិឱ្យពង្រីកការត្រួតពិនិត្យនូវការជួល នៅក្នុងទីក្រុងនានាទូទាំងរដ្ឋ, ដែលនាំមកនូវការការពារចាំបាច់ជាច្រើន នៅពេលដែលសហគមន៍ដែលមានពណ៌សម្បុរ និងសហគមន៍ដែលមានប្រាក់ចំណូលទាបយ៉ាងច្រើន ត្រូវការវា ដោយសារតែជំងឺរាតត្បាត COVID-19។

**សំណើរ 22 – ទេ (PROPOSITION 22 – NO)**

ក្រុមហ៊ុន Gig នានា ដូចជា Uber, Lyft, និង Doordash បដិសេធមិនអនុវត្តតាមច្បាប់ ដោយបង់ប្រាក់សម្រាប់ការការពារជាមូលដ្ឋានដែលអ្នកបើកបររបស់ពួកគេ បានទទួល។ ពួកគេបានសរសេរសំណើ ២២ ដើម្បីបង្កើតច្បាប់ថ្មីមួយ ដែលអនុវត្តចំពោះពួកគេ ដើម្បីអោយពួកគេអាចចាត់ទុកកម្មកររបស់ពួកគេ ជាអ្នកម៉ៅការ ដោយគ្មានការធានាសិទ្ធិ ឬផលប្រយោជន៍នានា នោះឡើយ។

**សំណើរ 23 – បាទ/ចាស (PROPOSITION 23 – YES)**

វិធានការណ៍នេះ តម្រូវឱ្យមានការការពារសុខភាព និងសុវត្ថិភាពជាច្រើន នៅគ្លីនិកលាងឈាម សម្រាប់អ្នកជំងឺទាំងអស់, ដែលភាគច្រើនជាមនុស្សពណ៌សម្បុរដែលមានប្រាក់ចំណូលទាប។

**សំណើរ 24 – អព្យាក្រឹត (PROPOSITION 24 – NEUTRAL)**

វិធានការណ៍នេះសរសេរចប់ទាំងស្រុងឡើងវិញ នូវច្បាប់ស្តីពីសិទ្ធិឯកជនរបស់អ្នកប្រើប្រាស់កាលីហ្វ័រញ៉ា, ដែលគ្រប់គ្រងនូវរបៀបដែលទិន្នន័យរបស់អ្នកប្រើប្រាស់ ត្រូវបានការពារ ឬលក់, និងបង្កើតទីភ្នាក់ងាររដ្ឋថ្មីមួយ ដើម្បីអនុវត្តនូវច្បាប់ឯកជន។ ខណៈពេលដែលវិធានការណ៍នេះ ដាក់ការទទួលខុសត្រូវកាន់តែច្រើនទៅលើសាជីវកម្មធំៗ, ផងដែរ វាក៏បង្កើតបន្ទុកបន្ថែមទៀតដល់ប្រជាជននៃពណ៌សម្បុរ និងមនុស្សដែលមានចំណូលទាប ដើម្បីការពារនូវភាពឯកជន តាមអ៊ីនធឺណិតរបស់ពួកគេ។

**សំណើរ 25 – អព្យាក្រឹត (PROPOSITION 25 – NEUTRAL)**

វិធានការណ៍នេះ នឹងសំរេចថាតើ SB 10 ត្រូវបានអនុវត្តន៍ ឬអត់, ដែលជាច្បាប់របស់រដ្ឋ ដែលលុបបំបាត់ ចោលនូវការបង់សាច់ប្រាក់ដើម្បីធានា និងជំនួសវាដោយប្រព័ន្ធវាយតម្លៃហានិភ័យមួយ ដែលត្រូវបានធ្វើការកំណត់ដោយចៅក្រម តាមរយៈសំណុំមួយនៃក្បួនដោះស្រាយបញ្ហា។

**ការបោះឆ្នោតរបស់យើង គឺជាអំណាចរបស់យើង! ចូលរួមពាក់ព័ន្ធជាមួយយុទ្ធនាការ របស់យើង:**

**LBForward.org/LBRising**
**#LBRising #LBVotes**